## សម្រេច

**មាត្រា ១** : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះសប្បុរសជន ដែលមានសទ្ធាជ្រះថ្លាជួយឧបត្ថម្ភម៉ាស៊ីនកិនស្រូវ១ គ្រឿង ដល់មជ្ឈមណ្ឌលអភិវឌ្ឍន៍ **ហ៊ុន សែន** នៅឃុំ ក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោមនេះ ÷

១_លោក INATOMI HIROKAZU

២_លោក TAKAI YOSHIKI

៣_លោក KENMOKU MASAYUKI

៤_លោក DOBASHI NAOKI

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

## ២ - សេចក្តីសម្រេច

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៦

### សេចក្តីសម្រេចលេខ ០១ សសរ

### ស្តីពី

### ការបង្កើតគណៈកម្មការតាមដាន និង ត្រួតពិនិត្យ អាគារស្រូវ ទីស្តីការគណៈរដ្ឋមន្ត្រី

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការមួយឈ្មោះថា " គណៈកម្មការតាមដាន និង ត្រួតពិនិត្យអាគារស្រុតទីស្តីការគណៈរដ្ឋមន្ត្រី " ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១_ឯកឧត្តម **ម៉ម សុផាណា** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ | ប្រធាន |
| ២_ឯកឧត្តម **ម៉ុន អ៊ុយ** | សហអនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣_ឯកឧត្តម **អ៊ុំ គីមសន** | សហអនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤_លោក **អ៊ុត ឈន** | ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច | សមាជិក |
| ៥_លោក **គួច គី** | អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញកិច្ច | សមាជិក |

៦_លោកតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្នែកនាយកដ្ឋានលទ្ធកម្មសាធារណៈ សមាជិក

**ប្រការ ២** : គណៈកម្មការនេះមានសិទ្ធិ និង ភារកិច្ច ÷

- សិក្សាស្រាវជ្រាវ តាមដាន និងត្រួតពិនិត្យការស្រុតនៃអាគារ ទីស្តីការគណៈរដ្ឋមន្ត្រី
- កោះអញ្ជើញអ្នកឯកទេសតាមក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិគ្រោះពិភាក្សាជាមួយឯកឧត្តម ទេសរដ្ឋមន្ត្រីប្រធាន គណៈកម្មាធិការជាតិរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- អញ្ជើញអ្នកឯកទេស បរទេសផ្នែកអាគារស្រុត ដើម្បីជួយសិក្សាស្រាវជ្រាវបន្ថែម
- ធ្វើរបាយការណ៍ ស្តីពីលទ្ធផលក្រោយការសិក្សាស្រាវជ្រាវរួច និងលើកវិធានការជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**ប្រការ ៣** : •គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។
•រាល់ការចំណាយជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៤** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

# II - ភាគខាងបណ្តាក្រសួង

## ២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល